long beach unified school district

*កម្មវិធីបង្គាត់* **BP 6020.1**

## *<u>ច្បាប់ទាក់ទងការរួមចំណែកពីមាតាបិតា នៅតាមសាលារៀនទទួលជំនួយ Title I</u>*

គណៈកម្មការនាយកផ្នែកសិក្សា ទទួលស្គាល់ថា មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សពីគ្រប់ឋានៈទាំងអស់នៅក្នុងក្រសួងអប់រំ ឪស្រ្ទីត គឺជាមនុស្សមានតម្លៃមកលើការអប់រំសិស្ស ។ គណៈកម្មការមានជំនឿថា កម្មវិធីសិក្សានៃសិស្ស គឺជាមុខងារទទួលខុសត្រូវស្មើគ្នារវាងសាលារៀន និង ក្រុមគ្រួសារ ។ ដើម្បីបញ្ជាក់អំពីកិច្ចការធ្វើរួមគ្នា គឺគណៈកម្មការ នាយកគ្រប់គ្រង និង បុគ្គលិកសាលារៀនតាំងចិត្តបង្កើតជាកិច្ចការផ្សេងៗសំរាប់ទាក់ទាញការរួមចំណែកពីមាតាបិតាតាមទំហំ និង គុណភាពត្រឹមត្រូវ ដើម្បីបង្កើនជាដៃគូរយ៉ាងស័ក្តិសិទ្ធរវាងសាលារៀន និង ផ្ទះ តាមរយៈ ...

1. ការទាក់ទាញចំណែកពីមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សសំរាប់បង្កើតរួមគ្នាអំពីគំរោងការណ៍ប្រចាំក្រសួងអប់រំ ឪស្រ្ទីត ដើម្បីផ្តល់ជាកម្មវិធីផ្សេងៗសំរាប់ជួយបង្កើនគុណភាពផ្នែកសិក្សានៅតាមសាលារៀន ដែលរាប់បញ្ចូលមាតាបិតាជាអ្នកជួយសើរើ និង ស្វែងរកមធ្យោបាយបង្កើនភាពលូតលាស់ ។

2. ធ្វើការពិគ្រោះជាបន្តបន្ទាប់ជាមួយមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សអំពីបញ្ហាផ្សេងៗ ដែលសាលារៀន និង មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សអាចធ្វើរួមគ្នាបាន ដើម្បីស្វែងរកគោលដៅ ការរៀបចំបង្កើត ការប្រតិបត្តិ និង ការស្ទង់វាស់មើលអំពីកម្មវិធីនៅក្នុងសាលារៀន ដើម្បីបញ្ជាក់អំពីភាពលូតលាស់ទៅមុខសំរាប់សិស្ស និង សាលារៀន ។

3. ផ្តល់ជំនួយផ្សេងៗចាំបាច់ ដើម្បីជួយសាលារៀនអំពីរបៀបរៀបចំ និង ធ្វើតាមគំរោងការណ៍ សំរាប់នាំមកភាពស័ក្តសិទ្ធចំពោះការរួមចំណែកពីមាតាបិតា/ក្រុមគ្រួសារ ដែលជួយបង្កើនដល់ភាពលូតលាស់ផ្នែកសិក្សាសំរាប់សិស្ស និង សាលារៀន ។ យ៉ាងតិចបំផុត គឺចំនួន 1% នៃជំនួយថវិការ Title I, Part A ប្រចាំក្រសួងអប់រំ ឪស្រ្ទីត នឹងត្រូវរក្សាទុកសំរាប់ប្រើមកលើ ការរួមចំណែកពីមាតាបិតា ហើយចំនួន 95% មកពី 1% នោះ គឺត្រូវចែកផ្តល់ទៅកាន់សាលារៀនសំរាប់ប្រើជាមួយកម្មវិធីផ្សេងៗទាក់ទងការរួមចំណែកពីមាតាបិតានៃសិស្ស Title I ។

4. ផ្តល់ជំនួយទៅកាន់ការប្រឹងប្រែងរបស់មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សអំពីការជួយសិស្សរបស់ពួកគាត់រៀងៗខ្លួនឲ្យយល់ និង រៀនទាន់ក៏រិតខ្នាតគំរូសិក្សា និង ការប្រឡង តែស្ត ទូទៅពីរដ្ឋ ដែលជាការតំរូវពីច្បាប់ Title I, Part A និង ការឃ្លាំតាមដានពីមាតាបិតាអំពីភាពលូតលាស់ផ្នែកសិក្សានៃសិស្សរបស់ពួកគាត់ ដែលរាប់ទាំងការចេះធ្វើកិច្ចការរួមជាមួយគ្រូបង្រៀនផង ដើម្បីបង្កើនភាពលូតលាស់ជាបន្តបន្ទាប់ ។

5. បង្កើនគុណភាពខ្ពស់សំរាប់ការរួមចំណែកពីមាតាបិតា និង ផ្តល់ឱកាសសំរាប់មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សពង្រឹងសមត្ថភាពរបស់ពួកគាត់រៀងៗខ្លួនអំពីផ្នែកអប់រំ និង ប្រើអក្សរ ដើម្បីជួយដាស់តឿនសិស្សរបស់ពួកគាត់ឲ្យបានប្រកបផ្នែកសិក្សា និង ចិត្តគំនិត រួមទាំងការរៀបចំនៅក្នុងផ្ទះជាកន្លែងមួយដ៏សំខាន់សំរាប់ធ្វើ ហូមវើក បង្កើនគោលគំនិតខ្ពស់ និង ដោះស្រាយបញ្ហាផ្សេងៗដោយខ្លួនឯង ។

6. ធ្វើការបញ្ជាក់ថា ពត៍មានទាក់ទងការប្រជុំ និង កម្មវិធីផ្សេងៗនៅតាមសាលារៀន និង សំរាប់មាតាបិតា គឺនឹងផ្ញើជូនមាតាបិតាស្របត្រឹមត្រូវមែនតាមរយៈបង្ហាញជាភាសាកំណើត ដែលពួកគាត់ងាយយល់ នៅពេលណាមានចំនួនសិស្សចុះឈ្មោះក្នុងក្រសួងអប់រំ ឪស្រ្ទីត ពី 15% ឡើងទៅ ដែលប្រើភាសាផ្សេងនៅឯផ្ទះ ក្រៅពីភាសា អង់គ្លេស ។ សំបុត្រផ្សេងៗផ្ញើជូនមាតាបិតា គឺប្រើជាភាសា អង់គ្លេស ដោយមានការសរសេរពន្យល់ភ្ជាប់ផងជាភាសាកំណើតរបស់ពួកគាត់ ។

7. ជំរាបជូនមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស ដែលមានឈ្មោះរៀននៅក្នុងសាលាអំពី a) មូលហេតុ ដែលសិស្សរបស់ពួកគាត់កំពុងរៀននៅក្នុងកម្មវិធីណាមួយ b) គោលដៅបង្ហាត់ និង ប្រភេទនៃកម្មវិធី និង c) សមត្ថភាពបង្ហាត់នៅក្នុងសាលារៀនរបស់សិស្ស រួមទាំងមធ្យោបាយផ្សេងៗ ដែលអាចជ្រើសរើសបានសំរាប់បញ្ជូនសិស្សរបស់ពួកគាត់ឲ្យទៅរៀនជាមួយ ។

8. បង្ហាត់មាតាបិតា/អ្នកគ្រប់គ្រងនៃសិស្ស និង គ្រូបង្រៀនឲ្យចេះបង្កើនជាដៃគូរវាងផ្ទះ និង សាលារៀន ដើម្បីជួយសិស្សឲ្យមានភាពលូតលាស់ និង បង្កើនទំនាក់ទំនងទៅមករវាងគ្នាយ៉ាងស្វិទ្ធស្នាលជាភាសា ដែលមាតាបិតាទាំងអស់អាចងាយយល់ និង ចែកផ្តល់ជា ក្រដាសកិច្ចសន្យា រវាងសាលារៀន និង ផ្ទះ ដែលបញ្ជាក់មុខងារទទួលខុសត្រូវស្មើគ្នារវាងបុគ្គលិកសាលារៀន មាតាបិតា និង សិស្សអំពីការបង្កើតភាពលូតលាស់ផ្នែកសិក្សាសំរាប់សិស្ស ។

9. ជំរុញមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សឲ្យហ៊ានទទួលមុខងារជាអ្នកដឹកនាំនៅតាមសាលារៀន និង ក្រសួងអប់រំ ឱស្រ្ទីគ អំពីផ្នែក: គ្រប់គ្រង ផ្តល់ឱវាទ និង ជួយសំរេចផ្សេងៗ និង ផ្តល់ឱកាសជូនមាតាបិតាឲ្យរៀនបញ្ចេញជាយោបល់ទៅកាន់ក្រសួងអប់រំ ឱស្រ្ទីគ បើសិនជាពួកគាត់មិនពេញចិត្តមកលើ ច្បាប់ទាក់ទងការរួមចំណែកពីមាតាបិតា ឬ គំរោងការណ៍តែមួយសំរាប់ភាពលូតលាស់ផ្នែកសិក្សានៃសិស្ស នៅតាមសាលារៀន ។

10. ផ្តល់កម្មវិធីហ្វឹកហ្វឺនទៅកាន់គ្រូបង្រៀន អ្នកផ្តល់ឱវាទ នាយកសាលា និង បុគ្គលិកផ្សេងៗ តាមរយៈទទួលយោបល់ពីមាតាបិតាអំពីរបៀបធ្វើទំនាក់ទំនង និង ការបង្កើតកម្មវិធីស័ក្តសិទ្ធសំរាប់បង្កើនដៃគូរវាងមាតាបិតា និង សាលារៀន ។

11. ទាក់ទាញមាតាបិតាឲ្យមានចំណែកនៅក្នុងការសើរើប្រចាំឆ្នាំអំពីចំណុចសំខាន់ៗ និង ភាពស័ក្តសិទ្ធនៃច្បាប់រៀបរាប់ ការរួមចំណែកពីមាតាបិតានៅក្នុងក្រសួងអប់រំ ឱស្រ្ទីគ និង ច្បាប់រៀបរាប់ ការរួមចំណែកពីមាតាបិតា នៅតាមសាលារៀន ដើម្បីបង្កើនគុណភាពផ្នែកសិក្សានៅក្នុងសាលារៀន និង រាប់បញ្ចូលផងទាំងការស្វែងរកបញ្ហាផ្សេងៗ ដែលនាំឲ្យរាំងស្ទះដល់ភាពលូតលាស់សំរាប់សិស្ស និង ការប្រើភស្តុតាងរកឃើញសំរាប់រៀបចំទាំងស្នានមកលើមធ្យោបាយកាន់តែស័ក្តសិទ្ធ ដែលទាក់ទងជាមួយការរួមចំណែកពីមាតាបិតា និង ការជួយកែប្រែច្បាប់ ទៅតាមការចាំបាច់ ។

12. ចាត់ចែង និង រាប់បញ្ចូលកម្មវិធីសំរាប់ការរួមចំណែកពីមាតាបិតានៅក្នុង Title I, Part A ទៅជាមួយកម្មវិធីផ្សេងៗ ដូចជា: Child Development Center (ស៊ីឌីស៊ី) ហេដស្តាត និង ព្រីស្គូល ប្រចាំក្រសួងអប់រំ ឱស្រ្ទីគ ដើម្បីជំរុញការចូលរួមចំណែកពីមាតាបិតាកាន់តែច្រើនសំរាប់ជួយសិស្សថ្នាក់ ព្រីស្គូល ប្រកបជោគជ័យកាន់តែខ្ពស់ ។

13. ចាត់ចែង និង រក្សា មជ្ឈមណ្ឌលមាតាបិតា (ស្របតាមសមត្ថភាពថវិការ) ជាកន្លែងផ្តល់: ថ្នាក់បង្ហាត់អក្សរ, កិច្ចការសំរាប់យកទៅធ្វើនៅតាមផ្ទះ និង កម្មវិធីណែនាំសំរាប់មាតាបិតាតាមសេចក្តីត្រូវការអំពីរបៀបជួយសិស្សរបស់ពួកគាត់ឲ្យរៀនប្រកប ។

14. ជួយមាតាបិតា/អ្នកគ្រប់គ្រងនៃសិស្សឲ្យបានទទួលជំនួយតាមសេចក្តីត្រូវការពីក្រសួងអប់រំ ឌីស្ត្រិគ និង ក្រសួងផ្សេងៗនៅតាមសហគមន៍ រួមទាំងចែកផ្តល់ជំនួយគាំទ្រយ៉ាងសមរម្យសំរាប់កម្មវិធីទាក់ទងមាតាបិតា ដូចអ្វី ដែលមាតាបិតាបានស្នើសុំ ។

15. បង្កើតជា ក្រុមប្រឹក្សាផ្តល់ឱវាទ ការិត ឌីស្ត្រិគ សំរាប់មាតាបិតា (ឌីខាក់) ដោយជ្រើសរើសយកអ្នកតំណាងមកពីសាលារៀននិមួយៗ ដើម្បីផ្តល់ជាគោលគំនិតមកលើបញ្ហាផ្សេងៗទាក់ទងការរួមចំណែកពីមាតាបិតា, ជំនួយថវិការ Title I នៅតាមសាលារៀន និង ចំណេះយល់ដឹងអំពីការរៀបចំកម្មវិធី ។

ដកស្រង់ពីច្បាប់:

EDUCATION CODE
11500-11506 កម្មវិធីសំរាប់បង្កើនការរួមចំណែកពីមាតាបិតា
UNITED STATES CODE, TITLE 20
6301 គោលដៅនៃកម្មវិធី
6318 ការរួមចំណែកពីមាតាបិតា

បានរៀបចំបង្កើតនៅ:

ថ្ងៃទី28 ខែមករា 1991

បានកែប្រែឡើងវិញនៅ:

ថ្ងៃទី1 ខែមិនា 1994
ថ្ងៃទី6 ខែកុម្ភៈ 2001
ថ្ងៃទី7 ខែមិនា 2006
ថ្ងៃទី12 ខែវិច្ឆិកា 2007
ថ្ងៃទី16 ខែកុម្ភៈ 2010
ថ្ងៃទី5 ខែកក្កដា 2011
**ថ្ងៃទី6 ខែធ្នូ 2017**

LONG BEACH UNIFIED SCHOOL DISTRICT